អង្គរបុរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## ក្រោមប្រធានបទ ទំនាក់ទំនងរវាងសីលសមាធិ និងបញ្ញា

website ÷ www.hoksavann.org
ថ្ងៃទី២២ កញ្ញា ២០០៨



ដូចបានពោលមកហើយ សីលសមាធិបញ្ញា ឬទាន សីលភាវនាដែលសង្ខេបមកពីអដ្ឋង្គិកមគ្គ ប្រែថាមគ្គប្រកបដោយអង្គ៨ ជាផ្លូវប្រតិបត្តិឆ្ពោះទៅរកការរំដោះទុក្ខ ពោលគឺព្រះនិព្វាន ។ សីលសមាធិបញ្ញានេះមានទំនាក់ទំនងគ្នា ដែលអ្នកប្រាថ្នាចេញចាកទុក្ខត្រូវប្រតិបត្តិទាំងបី ។ បានសេចក្តីថា មគ្គមានអង្គ៨ជាផ្លូវដ៏ត្រង់ក្នុងដំ-ណើរឆ្ពោះទៅរកការរំដោះទុក្ខ ត្រូវអនុវត្តទាំង៨ចោលណាមួយពុំបាន ព្រោះខ្វះអង្គឲ្យសម្រេចក្នុងការរំដោះទុក្ខ ។ បើនិយាយអំពីអានិសង្សឲ្យដាច់ដោយឡែកៗពីគ្នា គឺសីលសំរាប់លះកិលេសយ៉ាងគ្រោតគ្រាត ដែលនាំឲ្យមនុស្សសត្វសាងបាបកម្មធ្ងន់ៗ ដូចជាសម្លាប់មនុស្សសត្វ លួចទ្រព្យសម្បត្តិអ្នកដទៃជាដើម សមាធិលះកិលេសយ៉ាងកណ្តាល បានដល់នីវរណធម៌ទាំង៥មានកាមច្ឆន្ទៈជាដើម បញ្ញាលះកិលេសយ៉ាងល្អិតមានអវិជ្ជាជាដើម ។ ហេតុអ្វីបានត្រូវលះកិលេសទាំងអស់នេះ ព្រោះកិលេសទាំងនេះចងសត្វទុកក្នុងភពហៅថាកិលេសវដ្តៈ ។ រួមសេចក្តីមក សីលសមាធិបញ្ញានេះ សំរាប់លះកិលេសតណ្ហាទាំងអស់ ដោយគ្មានសេសសល់ ទើបរំលត់ទុក្ខដោយដាច់ខាត ។ ប្រៀបដូចជម្ងឺផ្លូវកាយ ដែលកើតរោគជាច្រើនយ៉ាង ថ្នាំដែលត្រូវយកមករំងាប់ជម្ងឺនោះ ក៏ត្រូវមានច្រើនយ៉ាងដែរ ។ រោគប្រៀបដូចកិលេស ឯថ្នាំប្រៀបដូចសីលសមាធិបញ្ញា ។

ការប្រតិបត្តិឲ្យកើតមានសមាធិនិងវិបស្សនា ត្រូវមានសីលជាខាងដើម

ប៉ុន្តែបញ្ហាក្នុងពេលនេះចង់ដឹងថា តើត្រូវប្រតិបត្តិឲ្យកើតចិត្តជាសមាធិសិនទើបបង្អោនចិត្តពិចារណានូវវិបស្សនាជាក្រោយ ឬក៏ចំរើនវិបស្សនាតែម្តងបានដែរ ? ព្រះពុទ្ធសំដែងធម៌ទេសនាតាមឧបនិស្ស័យរបស់មនុស្សសត្វ ។ សត្វខ្លះបានស្តាប់ធម៌ទេសនារបស់ព្រះពុទ្ធ បានដល់នូវព្រះត្រៃសរណគមន៍ គឺជឿគុណព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ។ សត្វខ្លះបានធ្វើទាន រក្សាសីល ហើយសត្វខ្លះបានចំរើនសមថកម្មដ្ឋាន ។ មានសត្វខ្លះ មានឧបនិស្ស័យខ្ពស់បានចំរើន រហូតដល់វិបស្សនាតែម្តង ។ សូមបញ្ជាក់ថា ពាក្យថាសត្វដែលប្រើក្នុងព្រះធម៌ដូចពាក្យថា ព្រះពុទ្ធប្រោសសត្វ បានសេចក្តីថា ព្រះអង្គសំដែងធម៌ទេសនា ប្រោសមនុស្សទេវតា ព្រះឥន្ទព្រះព្រហ្មជាដើម ពុំមែនប្រោសតែសត្វតិរច្ឆានទេ ព្រោះពាក្យថាសត្វប្រែថា អ្នកជាប់ជំពាក់ក្នុងអារម្មណ៍ គឺសត្វក្នុងភពទាំងបីតែងជាប់ជំពាក់ក្នុងអារម្មណ៍ វៀរលែងតែព្រះនិព្វានទើបមិនឈ្មោះថាសត្វ ព្រោះព្រះនិព្វានចេញផុតពីសង្ខតធម៌ទាំងអស់ ។ ដូច្នេះយើងអាចពោលថា សត្វតិរច្ឆានសត្វមនុស្ស សត្វទេវតា សត្វព្រហ្មជាដើម ព្រោះសុទ្ធតែជាប់ជំពាក់ក្នុងអារម្មណ៍ ប៉ុន្តែពួកសត្វទាំងនោះមានគុណធម៌ខ្ពស់ទាបជាងគ្នា ដូចជាមនុស្សជាសត្វដែរ ប៉ុន្តែជាសត្វពិសេស គឺជាអ្នកដឹងខុសត្រូវបុណ្យបាបគុណទោស ។ ដូចបានពោលមកហើយ បើអ្នកទើបតែបានអប់រំចិត្តជាដំបូង បញ្ញាស្មារតីនៅទប់ខ្សោយ គួរចំរើនសមថកម្មដ្ឋាន ឬសមាធិកម្មដ្ឋានជាមុន ដើម្បីហាត់ផ្លូវចិត្តឲ្យស្ងប់នូវនីវរណធម៌ទាំង៥ ព្រោះអ្វី ? ព្រោះថា បើបុគ្គលមាននីវរណធម៌ទាំង៥ នីវរណធម៌ណាមួយកើតឡើងខ្លាំង ដូចចិត្តជាប់នឹងកាមខ្លាំង ឬកើតគំនិតព្យាបាទខ្លាំង មិនអាចលើកយកវិបស្សនាមកចំរើនបានឡើយ ព្រោះសមាធិជាបទដ្ឋាន គឺជាហេតុជិតរបស់វិបស្សនា ។ បន្ទាប់ពីបានចំរើនឲ្យកើតជាសមាធិហើយ អាចបង្អោនចិត្តចំរើនវិបស្សនាក្នុងពេលជាមួយគ្នា បានគ្រាន់តែប្តូរអារម្មណ៍ប៉ុណ្ណោះ ។ សូមបញ្ជាក់ឡើងវិញថា សមាធិមានមុខនាទីឲ្យស្ងប់នីវរណធម៌ ឯវិបស្សនាពិចារណារកការពិតក្នុងខន្ធ ធាតុអាយតនៈ ថាប្រព្រឹត្តទៅជាអនិច្ចំ ទុក្ខំ និងអនត្តា ។ របៀបចំរើនសមថកម្មដ្ឋាន ដូចបានពន្តល់ខ្លះមកហើយ អាចជ្រើសរើសកម្មដ្ឋានណាមួយមកចំរើនបានតាមសមគួរដល់ចរិតរបស់ខ្លួន ។ ចំណែកបុគ្គលដែលមានឧបនិស្ស័យខ្ពស់ មានបញ្ញាច្រើន ស្តើងដោយកិលេសតណ្ហា អាច

លើកយកវិបស្សនាមកចំរើនតែម្តង ព្រោះពេលនោះមានសីលនិងសមាធិនៅជាមួយគ្នាហើយ ។ របៀបចំរើនវិបស្សនាបានពន្យល់ខ្លះហើយ ជាពិសេសបានលើកយកសតិបដ្ឋាន៤ ជាវិធីមានបច្ចេកទេសខ្ពស់ ចំរើនទៅឆាប់កើតបញ្ញាឃើញការកើតរលត់របស់សង្ខារ (ខន្ធ៥) ។ កំណត់ផ្លូវចិត្តពិចារណារហូតដល់កើតបញ្ញាឃើញថា កាយ វេទនា ចិត្ត ធម្មៈ (អារម្មណ៍) គ្រាន់តែជាកាយវេទនាចិត្ត និងធម្មៈ ពុំមែនជាសត្វជាបុគ្គល មានសភាពសោះសូន្យទទេ ។ គោលបំណងសំខាន់របស់វិបស្សនា គឺការលះតណ្ហានិងទិដ្ឋិ ។ តណ្ហាគឺសេចក្តីប្រាថ្នាឯទិដ្ឋិគឺការយល់ខុស ។ សម្មាទិដ្ឋិ គឺការយល់ត្រូវ ដូចជាយល់ត្រូវក្នុងអរិយសច្ច៤យល់ត្រូវក្នុងខន្ធ៥ថាមានលក្ខណៈប្រព្រឹត្តទៅជាអនិច្ចំ ទុក្ខំ និងអនត្តាជាដើម ។ កាលណាបញ្ញាកើតឡើងតាមផ្លូវវិបស្សនាឃើញការពិត តណ្ហានឹងត្រូវរលត់ដោយស្វ័យប្រវត្តិ ។

សូមបញ្ជាក់ឡើងវិញ ព្រះនិព្វានជាឈ្មោះការរលត់តណ្ហា ឯពាក្យថានិរោធ ជាឈ្មោះការរលត់ទុក្ខ ដោយខន្ធ៥ពុំកើតមានតទៅទៀត ។ ចំពោះសេចក្តីសុខរបស់ព្រះនិព្វាន គឺសុខព្រោះពុំកង្វល់នឹងអ្វីទាំងអស់ បើមានខន្ធ៥ កង្វល់នឹងការចាស់ ឈឺ ស្លាប់ និងកង្វល់ជាច្រើនទៀតរាប់មិនអស់ ទទួលទុក្ខទាំងផ្លូវកាយនិងផ្លូវចិត្ត ។ អ្នកកាន់ពុទ្ធសាសនាគួរប្រើពាក្យឲ្យត្រឹមត្រូវតាមសភាពពិតអំពីព្រះនិព្វាន ។ កុំប្រើពាក្យថាស្ថានព្រះនិព្វាន ព្រោះព្រះនិព្វានពុំមែនជាស្ថានទេ ។ កុំប្រើពាក្យថា ទៅកាន់ទីរំលត់ទុក្ខ គឺព្រះនិព្វាន ព្រោះប្រើពាក្យថាទី ហាក់ដូចព្រះនិព្វានមានទីតាំង ត្រង់ទីនេះត្រូវប្រើពាក្យថា ការរំលត់ទុក្ខវិញ ។ ដូចជាភ្លើងចង្កៀងរលត់ តើភ្លើងវាទៅណា ពុំមែនឆ្លើងបាត់ទៅណាទេ ព្រោះភ្លើងឆេះមកពីមានហេតុបច្ច័យជាគ្រឿងផ្សំ គឺមានប្រឆេះ មានប្រេង ហើយគេអុជ ទើបឆ្លើងឆេះឡើង បើអស់គ្រឿងផ្សំទាំងនេះ ភ្លើងក៏គ្មានដែរ ។ យ៉ាងណាមិញ ព្រះនិព្វានជាឈ្មោះការរលត់តណ្ហា ដែលមិនអាចបង្កើតខន្ធ៥ដែលជាតួទុក្ខតទៅទៀត ។ ដូច្នេះឈ្មោះព្រះនិព្វាន ជាឈ្មោះការរលត់នៃសង្ខារធម៌ ពុំមែនជាតួអ្វីឡើយ ។ ចំពោះបុគ្គលចំរើនធម៌វិញ អាចចំរើនឲ្យកើតសមាធិមុនក៏បាន អាចចំរើនវិបស្សនាតែម្តងក៏បាន ស្រេចតែនិស្ស័យវាសនា ដែលអាចចំរើនបាន ។ សម័យពុទ្ធកាល មានភិក្ខុខ្លះបានស្តាប់ធម៌ទេសនាព្រះពុទ្ធ បានសំរេចមគ្គផល

ដោយពិចារណាតាមធម៌ព្រះពុទ្ធសំដែង  គឺមានសីលសមាធិបញ្ញានៅក្នុងចិត្តពេលនោះតែម្តង មិនឃើញនិយាយថា ចំរើនសមាធិឲ្យកើតសិន ទើបចំរើនវិបស្សនាជាក្រោយយ៉ាងនេះឡើយ ។៚